# ប័ណ្ណផ្សព្វផ្សាយអំពីសិទ្ធិពេលឃាត់ខ្លួនដោយមន្ត្រីនគរបាលយុត្តិធម៌

## សូមអានព័ត៌មាននៅក្នុងប័ណ្ណនេះ ប្រសិនបើអ្នកត្រូវបានចាប់ខ្លួន ឬឃាត់ខ្លួន!

យោងតាមច្បាប់កម្ពុជា ជនណាក៏ដោយដែលត្រូវបានមន្ត្រីនគរបាលយុត្តិធម៌ចាប់ខ្លួន ឬឃាត់ខ្លួន មានសិទ្ធិជាមូលដ្ឋានមួយចំនួនដើម្បីការពារខ្លួន។ សិទ្ធិទាំងនេះគឺជារបស់អ្នកដែលត្រូវចាប់ខ្លួន ឬឃាត់ខ្លួន ហើយសិទ្ធិទាំងនេះមិនត្រូវបានដកហូតពីអ្នកទេ។ ប្រសិនបើអ្នកគ្រាន់តែត្រូវបានមន្ត្រីនគរបាលយុត្តិធម៌ចាប់ខ្លួន ឬឃាត់ខ្លួន អ្នកមានសិទ្ធិដូចខាងក្រោមនេះ៖

**ប្រសិនបើអ្នកមានអាយុក្រោម ១៤ ឆ្នាំ អ្នកមិនត្រូវបានចាប់ខ្លួន ឬឃាត់ខ្លួននោះទេ។**

**សិទ្ធិដឹងពីមូលហេតុចាប់ខ្លួន ឬឃាត់ខ្លួន៖** មន្ត្រីនគរបាលយុត្តិធម៌ ត្រូវប្រាប់អ្នកភ្លាមៗពីមូលហេតុនៃការចាប់ខ្លួន ឬឃាត់ខ្លួន។ អ្នកអាចត្រូវបានចាប់ខ្លួនតែតាមដីការបស់តុលាការ ឬក៏កំពុងតែប្រព្រឹត្តអំពើល្មើសច្បាប់ប៉ុណ្ណោះ។ មន្ត្រីនគរបាលយុត្តិធម៌ ក៏អាចឃាត់ខ្លួនអ្នកជាបណ្តោះអាសន្នបានដែរ ប្រសិនបើគេយល់ថា អ្នកបានរំលោភច្បាប់ ឬមិនព្រមសហការជាមួយមន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត។

**មន្ត្រីនគរបាលយុត្តិធម៌មិនអាចឃាត់ខ្លួនអ្នកលើសពី ៤៨ ម៉ោងទេ (២ ថ្ងៃ) បន្ទាប់ពីនោះ អ្នកត្រូវតែទទួលបានការចោទប្រកាន់ ឬត្រូវតែបានដោះលែង។**

**សិទ្ធិមានមេធាវី៖** អ្នកអាចពឹងពាក់រកមេធាវីបាន។ បន្ទាប់ពីការឃាត់ខ្លួន ២៤ ម៉ោង អ្នកត្រូវតែទាមទារជួបជាមួយមេធាវី ឬជនណាម្នាក់តាមតែអ្នកជ្រើសរើស។ ប្រសិនបើអ្នកមិនមានលទ្ធភាពបង់ថ្លៃសេវាឲ្យមេធាវីបាន មានអង្គការមេធាវីមិនយកកំរៃមួយចំនួនអាចជួយអ្នកបាន។ សូមអ្នកសួរមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីទំនាក់ទំនងជាមួយអង្គការទាំងនោះ។

**សិទ្ធិរក្សាភាពស្ងៀមស្ងាត់៖** អ្នកអាចរក្សាភាពស្ងៀមស្ងាត់ មិនឆ្លើយនឹងសំណួររបស់មន្ត្រីនគរបាលយុត្តិធម៌បាន ដោយរង់ចាំរហូតដល់អ្នកមានមេធាវី។ គ្មាននរណាម្នាក់អាចបង្ខំអ្នកឲ្យឆ្លើយ ប្រសិនបើអ្នកមិនចង់ឆ្លើយនោះទេ។

**សិទ្ធិមិនឆ្លើយសារភាព៖** អ្នកមិនត្រូវសារភាពពីអ្វី ដែលអ្នកមិនបានប្រព្រឹត្តនោះទេ។ អ្នកអាចសារភាពពីអ្វីដែលអ្នកពិតជាបានធ្វើ ប្រសិនបើអ្នកចង់ ឬក៏អាចចាំដល់ពេលដែលអ្នកមានមេធាវី ទើបឆ្លើយតាមការផ្តល់យោបល់ពីមេធាវីក៏បាន។ គ្មាននរណាម្នាក់អាចបង្ខំឲ្យអ្នកទទួលសារភាពថាបានប្រព្រឹត្តល្មើសអ្វីមួយ ដោយការវាយដំអ្នក ឬគំរាមកំហែងអ្នក ឬគ្រួសារអ្នកនោះទេ។ ប្រសិនបើនរណាម្នាក់វាយដំធ្វើទារុណកម្មអ្នក ហើយបង្ខំឲ្យអ្នកឆ្លើយសារភាព នោះចំលើយសារភាពបែបនេះ មិនអាចយកជាការបានទេ និងមិនអាចយកមកប្រើប្រឆាំងនឹងអ្នកនៅតុលាការឡើយ។

**អ្នកត្រូវពិនិត្យមើលចំលើយរបស់អ្នកដែលបានឆ្លើយឲ្យបានច្បាស់ មុននឹងអ្នកផ្តិតម្រាមដៃ។** ប្រសិនបើមិនត្រឹមត្រូវដូចអ្វីដែលអ្នកបានឆ្លើយ អ្នកត្រូវតែទាមទារឲ្យធ្វើការកែតម្រូវមុននឹងអ្នកផ្តិតម្រាមដៃ។

**សិទ្ធិត្រូវបាននាំខ្លួនទៅតុលាការ៖** ក្រោយឃាត់ខ្លួនភ្លាម អ្នកត្រូវតែបាននាំខ្លួនទៅតុលាការឆាប់ៗ តាមដែលអាចធ្វើបាន។ តុលាការនឹងធ្វើការស៊ើបអង្កេតរឿងក្តីរបស់អ្នក និងធ្វើឲ្យប្រាកដប្រជាថា គ្មាននរណាម្នាក់ប្រព្រឹត្តមកលើអ្នកមិនបានត្រឹមត្រូវតាមច្បាប់នោះទេ។ ប្រសិនបើអ្នកត្រូវបានចាប់ខ្លួន ដោយសារតែអ្នកត្រូវបានកាត់ទោស និងផ្តន្ទាទោសដោយកំបាំងមុខនោះ អ្នកមានសិទ្ធិសុំឲ្យមានការកាត់ក្តីម្តងទៀត។ សូមសាកសួរមេធាវីរបស់អ្នកពីការអនុវត្តសិទ្ធិនេះ។

**សិទ្ធិប្រាប់ដល់អ្នកផ្ទះពីការចាប់ខ្លួន ឬឃាត់ខ្លួន៖** អ្នកត្រូវប្រាប់ដល់អ្នកផ្ទះឲ្យបានដឹងពីការចាប់ខ្លួន ឬឃាត់ខ្លួន។ ប្រសិនបើអ្នកមានអាយុក្រោម ១៨ ឆ្នាំ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវប្រាប់ឪពុក-ម្តាយ ឬអាណាព្យាបាលរបស់អ្នកអំពីការចាប់ខ្លួន ឬឃាត់ខ្លួននេះ។

**សិទ្ធិប្តឹងពីការបដិសេធសិទ្ធិរបស់អ្នក៖** មន្ត្រីនគរបាលយុត្តិធម៌គ្រប់រូប និងមន្ត្រីដែលមានអំណាចចាប់ខ្លួន ឬឃាត់ខ្លួន សុទ្ធតែទទួលបានការបណ្តុះបណ្តាល និងយល់ដឹងថាពួកគេត្រូវគោរពសិទ្ធិទាំងអស់ដែលមានចែងនៅក្នុងប័ណ្ណនេះ។ ប្រសិនបើអ្នកគិតថា សិទ្ធិរបស់អ្នកត្រូវបានគេបដិសេធ អ្នកអាចប្តឹងទៅមេធាវីរបស់អ្នក ឬទៅព្រះរាជអាជ្ញា ឬចៅក្រមដែលកាន់រឿងក្តីរបស់អ្នកបាន។

**ទារុណកម្ម គឺជាបទឧក្រិដ្ឋនៅកម្ពុជា។ នរណាក៏ដោយដែលធ្វើឲ្យអ្នកឈឺចាប់ ឬគំរាមកំហែងធ្វើឲ្យអ្នកឈឺចាប់ ជននោះអាចត្រូវបានចោទប្រកាន់តាមផ្លូវច្បាប់។** អ្នកត្រូវប្រាប់រឿងនេះដល់មេធាវីរបស់អ្នក ដល់ព្រះរាជអាជ្ញា ឬចៅក្រម ពីការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញ ឬការគំរាមកំហែងចំពោះអ្នកដោយមន្ត្រីខាងចាប់ចង។ ព្រះរាជអាជ្ញាត្រូវតែធ្វើឲ្យប្រាកដថា បណ្តឹងរបស់អ្នកត្រូវបានស៊ើបអង្កេត ហើយត្រូវចោទប្រកាន់ជនណាដែលសង្ស័យពីការប្រព្រឹត្តទារុណកម្ម។

វាក៏ជាបទឧក្រិដ្ឋផងដែរ ចំពោះជនណាដែលបានសុំអ្នក ឬគ្រួសារអ្នក ឲ្យបង់លុយចំពោះការដោះលែងអ្នក។ **អ្នកមិនគួរឲ្យលុយទៅជននោះទេ។**

**ទោះជាអ្នកបានប្រព្រឹត្តបទល្មើសក៏ដោយ ក៏អ្នកមានសិទ្ធិមនុស្សជាមូលដ្ឋាន អនុលោមតាមច្បាប់កម្ពុជាដែរ។**

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
កម្ពុជា

បោះពុម្ពផ្សាយដោយមានកិច្ចសហការរវាងការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌-ខែមេសា ឆ្នាំ២០១២, យោងតាមមាត្រា ៩៣ ដល់ ១០៣, មាត្រា ៦៤ ដល់ ៦៦ និងមាត្រា ១៨៩-១៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ព្រមទាំងមាត្រា ៣១, ៣៨ និង ៣៩ នៃរដ្ឋធម្មនុញ្ញ។ សិទ្ធិដទៃទៀតក៏អាចអនុវត្តបានដែរ។